ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ថ្ងៃ ព្រហស្បតិ៍ ១៤កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨

ក្រសួងព័ត៌មាន ក្រសួងមហាផ្ទៃ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
លេខៈ ១៧០ ប្រក.អន្តរក្រ.

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និង បណ្តាញទំនាក់ទំនងសង្គម ដែលដំណើរការតាមប្រព័ន្ធអ៊ីនធឺណិត នៅព្រះរាជាណាចក្រកម្ពុជា

**រដ្ឋមន្ត្រីក្រសួងព័ត៌មាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ០២/ន.ស/៩៤ ចុះថ្ងៃទី២០ខែកក្កដាឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៤ ចុះថ្ងៃទី២៤ខែមករាឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
-បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ខែមករាឆ្នាំ១៩៩៦ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
-បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ខែមករាឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
-បានឃើញព្រះរាជក្រមលេខនស/រកម/០៨៩៥/០៧ ចុះថ្ងៃទី០១ខែកញ្ញាឆ្នាំ១៩៩៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបសារព័ត៌មាន
-បានឃើញព្រះរាជក្រមលេខនស/រកម/១២១៥/១៧ ចុះថ្ងៃទី១៧ខែធ្នូឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីទូរគមនាគមន៍
-បានឃើញអនុក្រឹត្យលេខ៧០អនក្រ.បក ចុះថ្ងៃទី០៥ខែសីហាឆ្នាំ១៩៩៩ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន
-បានឃើញអនុក្រឹត្យលេខ[illegible] អនក្រ.បក ចុះថ្ងៃទី[illegible]ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋានរដ្ឋបាល និងសោតទស្សន៍ ជាអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍របស់ក្រសួងព័ត៌មាន
-បានឃើញអនុក្រឹត្យលេខ[illegible]អនក្រ.បក ចុះថ្ងៃទី១៩ខែសីហាឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ

-បានឃើញអនុក្រឹត្យលេខ៣៩អនក្រ.បក ចុះថ្ងៃទី២៨ខែមេសាឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។
-យោងតាមតម្រូវការចាំបាច់របស់ក្រសួងព័ត៌មាន ក្រសួងមហាផ្ទៃ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
-យោងតាមសំណូមពររបស់ក្រសួងព័ត៌មាន ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧។

## សម្រេច

**ប្រការ១.**_

ប្រកាសនេះគោលបំណងគ្រប់គ្រងការផ្សព្វផ្សាយរាល់ខ្លឹមសារព័ត៌មាន ឬសារជាអក្សរ សំឡេង រូបភាព វីដេអូ និង/ឬ ទម្រង់ផ្សេងៗទៀត តាមគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម ដែលដំណើរការតាមប្រព័ន្ធអ៊ីនធឺណិត (Internet) នៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងព័ត៌មាន និងច្បាប់ស្តីពីរបបសារព័ត៌មាន។

**ប្រការ២.**_

ប្រកាសនេះ មានគោលដៅប្រឆាំង ទប់ស្កាត់ រាល់ការផ្សព្វផ្សាយ ឬ ការចែកចាយខ្លឹមសារព័ត៌មាន ឬ សារជាអក្សរ សំឡេង រូបភាព វីដេអូ និង/ឬ ទម្រង់ផ្សេងៗទៀត ដែលមានចេតនាបង្កជាចលាចលបណ្តាលឲ្យអន្តរាយដល់វិស័យការពារជាតិ សន្តិសុខជាតិ ទំនាក់ទំនងជាមួយប្រទេសដទៃ សេដ្ឋកិច្ចជាតិ សណ្តាប់ធ្នាប់សាធារណៈ ការរើសអើង និងវប្បធម៌ ប្រពៃណីជាតិ។

**ប្រការ៣.**_

ប្រកាសនេះ មានវិសាលភាពអនុវត្តទៅលើការផ្សព្វផ្សាយតាមគេហទំព័រ និងរាល់បណ្តាញទំនាក់ទំនងសង្គម ដែលដំណើរការតាមប្រព័ន្ធអ៊ីនធឺណិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤.**_

ដើម្បីធានាការអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពខ្ពស់ ក្រសួងព័ត៌មាន ក្រសួងមហាផ្ទៃ និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវចាត់តាំងអង្គភាពជំនាញជាសេនាធិការ ដើម្បីងាយស្រួលក្នុងកិច្ចសហការធ្វើការតាមដាន សិក្សា ស្រាវជ្រាវ ស្វែងរក ការធ្វើអាជីវកម្ម និងការផ្សព្វផ្សាយល្មើសច្បាប់តាមគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម ដើម្បីចាត់វិធានការតាមនីតិវិធីច្បាប់។

អង្គភាពជំនាញដែលមានភារកិច្ចអនុវត្តប្រកាសនេះ មានដូចខាងក្រោម៖

- ក្រសួងព័ត៌មាន ប្រតិបត្តិការដោយ អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍
- ក្រសួងមហាផ្ទៃ ប្រតិបត្តិការដោយ អគ្គស្នងការនគរបាលជាតិ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ប្រតិបត្តិការដោយ និយ័តករទូរគមនាគមន៍កម្ពុជា។

**ប្រការ៥.**_

ស្ថាប័ន អង្គភាពជំនាញនីមួយៗ ត្រូវបំពេញភារកិច្ចតាមភារកិច្ចរៀងៗខ្លួន និងត្រូវសហការគ្នា និង/ឬ សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត ដើម្បីចាត់វិធានការប្រឆាំង ទប់ស្កាត់ការផ្សព្វផ្សាយរាល់ខ្លឹមសារព័ត៌មាន ឬ សារជាអក្សរ សំឡេង រូបភាព វីដេអូ និង/ឬ ទម្រង់ផ្សេងៗទៀតដែលមានចេតនាបង្កភាពចលាចល បណ្តាលឲ្យអន្តរាយដល់វិស័យការពារជាតិ សន្តិសុខជាតិ ទំនាក់ទំនងជាមួយប្រទេសដទៃ សេដ្ឋកិច្ចជាតិ សណ្តាប់ធ្នាប់សាធារណៈ ការរើសអើង និងវប្បធម៌ ប្រពៃណីជាតិ។

ស្ថាប័ន អង្គភាពជំនាញនីមួយៗ ត្រូវសុំគោលការណ៍ពីថ្នាក់ដឹកនាំក្រសួង ស្ថាប័នសាមីដើម្បីអនុវត្តសកម្មភាពការងាររបស់ខ្លួន និងរាយការណ៍ជូនថ្នាក់ដឹកនាំក្រសួង ស្ថាប័នសាមី អំពីលទ្ធផលការងារដែលបានអនុវត្តជាប្រចាំ។

**ប្រការ៦.**_

*ក្រសួងព័ត៌មានត្រូវធានានូវ៖*

*ក-គ្រប់គ្រងព័ត៌មានដែលផ្សព្វផ្សាយតាមប្រព័ន្ធអេឡិចត្រូនិកជាអាទិ៍: រាល់ខ្លឹមសារព័ត៌មាន ឬ សារជាអក្សរ សំឡេង រូបភាព វីដេអូ និង/ឬ ទម្រង់ផ្សេងៗទៀត តាមគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គមដែលដំណើរការតាមប្រព័ន្ធអ៊ីនធឺណិត (Internet) នៅក្នុងព្រះរាជាណាចក្រកម្ពុជា។*

*ខ-ចាត់វិធានការលើប្រព័ន្ធផ្សព្វផ្សាយតាមអេឡិចត្រូនិក ដែលមានច្បាប់អនុញ្ញាតធ្វើអាជីវកម្មពីក្រសួងព័ត៌មាន ដែលធ្វើការផ្សព្វផ្សាយល្មើសច្បាប់។*

*គ-ផ្តល់ព័ត៌មានជូនក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ចាត់វិធានការបិទគេហទំព័រ និង/ឬ Page បណ្តាញទំនាក់ទំនងសង្គម ដែលបើកអាជីវកម្មផ្សព្វផ្សាយដោយខុសច្បាប់ និង/ឬ ការផ្សព្វផ្សាយព័ត៌មានដោយចេតនា ដើម្បីបង្កជាចលាចលក្នុងសង្គមធ្វើឲ្យអន្តរាយដល់វិស័យការពារជាតិ សន្តិសុខជាតិ ទំនាក់ទំនងជាមួយប្រទេសដទៃ សេដ្ឋកិច្ចជាតិ សណ្តាប់ធ្នាប់សាធារណៈ ការរើសអើង និងវប្បធម៌ប្រពៃណីជាតិ។*

*ឃ-សហការជាមួយក្រសួងមហាផ្ទៃ និងស្ថាប័នពាក់ព័ន្ធចាត់វិធានការបង្រ្កាបការធ្វើអាជីវកម្មតាមប្រព័ន្ធអ៊ីនធឺណិតដែលល្មើសច្បាប់។*

*ង-ផ្តល់ព័ត៌មានជូនក្រសួងមហាផ្ទៃ នូវអាសយដ្ឋាន គេហទំព័រ និងគណនី បណ្តាញទំនាក់ទំនងសង្គមទាំងឡាយណាដែលធ្វើការផ្សព្វផ្សាយល្មើសច្បាប់ ដើម្បីចាត់វិធានការតាមនីតិវិធីច្បាប់។*

**ប្រការ៧.**_

*ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ត្រូវធានានូវ៖*

*ក-ចាត់វិធានការតឹងរឹងចំពោះក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិតទាំងអស់ ដែលកំពុងដំណើរការធ្វើអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា គ្មានច្បាប់អនុញ្ញាតពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។*

*ខ-តម្រូវឲ្យក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិតទាំងអស់ ដែលកំពុងប្រតិបត្តិការអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានកម្មវិធីសុហ្វវែរ និងបំពាក់ឧបករណ៍គ្រប់គ្រងអ៊ីនធឺណិត ដើម្បីងាយស្រួលក្នុងការច្រោះ (Filter) ឬ ធ្វើការរាំងខ្ទប់ (Block) ចំពោះគេហទំព័រ គណនី (Account) ឬ ទំព័រ (Page) របស់បណ្តាញទំនាក់ទំនងសង្គម ដែលធ្វើអាជីវកម្ម និង/ឬ ធ្វើការផ្សព្វផ្សាយល្មើសច្បាប់។*

*គ-សហការជាមួយក្រសួងព័ត៌មាន ឬ ក្រសួង ស្ថាប័នពាក់ព័ន្ធ និង/ឬ ស្នើសុំកិច្ចសហការពីក្រសួង ស្ថាប័នអន្តរជាតិពាក់ព័ន្ធដទៃទៀត រាំងខ្ទប់ (Block) ឬ បិទគេហទំព័រ និង/ឬ ទំព័រ (Page)បណ្តាញទំនាក់ទំនងសង្គម ដែលធ្វើអាជីវកម្មខុសច្បាប់ និង/ឬ ធ្វើការផ្សព្វផ្សាយល្មើសច្បាប់ ដែលមានលក្ខណៈញុះញង់ បំបែកបំបាក់សាមគ្គីភាព ការរើសអើង ចេតនាបង្កចលាចល ដែលអាចបណ្តាលឲ្យអន្តរាយដល់សន្តិសុខជាតិ ផលប្រយោជន៍សាធារណៈ និងសណ្តាប់ធ្នាប់សង្គមៗលៗ។*

*ឃ-សហការផ្តល់ព័ត៌មានជូនក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីចាត់វិធានការតាមនីតិវិធីច្បាប់។*

**ប្រការ៨.**_

*ក្រសួងមហាផ្ទៃត្រូវធានានូវ៖*

*ក-ធ្វើការសិក្សា ស្រាវជ្រាវ ស្វែងរកប្រភពគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម ដែលធ្វើការផ្សព្វផ្សាយល្មើសច្បាប់ បង្កចលាចលក្នុងសង្គមអាចបណ្តាលឲ្យអន្តរាយដល់វិស័យការពារជាតិ សន្តិសុខជាតិ ទំនាក់ទំនងជាមួយប្រទេសដទៃ សណ្តាប់ធ្នាប់សាធារណៈ ការរើសអើង និងវប្បធម៌*

ប្រពៃណីជាតិ ដើម្បីចាត់វិធានការតាមនីតិវិធីច្បាប់។

ខ-សហការផ្តល់ព័ត៌មានជូនក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីមានវិធានការចំពោះការធ្វើអាជីវកម្មប្រព័ន្ធផ្សព្វផ្សាយតាមគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម ដែលគ្មានច្បាប់អនុញ្ញាត។

គ-សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ចាត់វិធានការបង្ក្រាបបទល្មើសការធ្វើអាជីវកម្មតាមបណ្តាញទំនាក់ទំនងសង្គម ដែលប្រតិបត្តិការតាមប្រព័ន្ធអ៊ីនធឺណិត និង/ឬ ធ្វើការផ្សព្វផ្សាយព័ត៌មាន ឬសារជាអក្សរ សំឡេង រូបភាព វីដេអូ និង/ឬ ទម្រង់ផ្សេងៗទៀត ដែលល្មើសច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៩.**_

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១០.**_

អគ្គនាយកនៃអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍នៃក្រសួងព័ត៌មាន អគ្គស្នងការនគរបាលជាតិនៃក្រសួងមហាផ្ទៃ ប្រធាននិយ័តករទូរគមនាគមន៍កម្ពុជា នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ប្រធានមន្ទីរព័ត៌មានរាជធានី-ខេត្ត ស្នងការនៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍រាជធានី-ខេត្ត និងប្រធានស្ថាប័ន អង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសអន្តរក្រសួងនេះឲ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**រដ្ឋមន្ត្រី**
**ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

**ត្រាំ អ៊ីវតឹក**

**រដ្ឋមន្ត្រី**
**ក្រសួងព័ត៌មាន**

**ខៀវ កាញារីទ្ធ**

*<u>ចម្លងជូន</u>*

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ក្រសួង ស្ថាប័នពាក់ព័ន្ធ
-សាលារាជធានី ខេត្ត
-ក្រុមហ៊ុនអ៊ីនធឺណិតទាំងអស់
-ដូចប្រការ១០ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ